កាន់តែទុកចិត្ត កាន់តែចំរើន

ហត្ថាកសិករ លីមីតធីត

HATTHA KAKSEKAR LIMITED

# របាយការណ៍ត្រីមាសទី៣

ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩

Subsidiary of krungsri bank

A member of MUFG, a global financial group

## ទស្សនវិស័យ និងបេសកកម្ម

| | |
|---|---|
| ទស្សនវិស័យ | ជាគ្រឹះស្ថានហិរញ្ញវត្ថុដែលទទួលបានការកោតសរសើរខ្ពស់ និងជាជម្រើសដែលអតិថិជនពេញចិត្ត តាមរយៈបុគ្គលិកប្រកបដោយវិជ្ជាជីវៈ។ |
| បេសកកម្ម | យើងផ្តល់ជូនអតិថិជននូវដំណោះស្រាយហិរញ្ញវត្ថុ ដែលគួរឱ្យជឿទុកចិត្ត ងាយស្រួល និងប្រកបដោយភាពច្នៃប្រឌិត តាមរយៈបច្ចេកវិទ្យាឌីជីថល ដែលនាំមកនូវបទពិសោធន៍ល្អៗដល់អតិថិជន។ យើងប្តេជ្ញាចូលរួមចំណែកដល់ការរីកចម្រើនរបស់អតិថិជន និងសង្គម ប្រកបដោយចេរភាព។ |

## តម្លៃស្នូល

| | |
|---|---|
| ស្មោះត្រង់ | យើងប្តេជ្ញាធ្វើអ្វីដែលល្អ ប្រកបដោយភាពស្មោះត្រង់ ត្រឹមត្រូវ តម្លាភាព ទទួលខុសត្រូវ និងវិជ្ជាជីវៈ។ |
| ឧត្តមភាព | យើងប្តេជ្ញាធ្វើការងារប្រកបដោយឧត្តមភាពជាមួយកម្រិតបទដ្ឋានកាន់តែខ្ពស់ ហើយយើងចាប់យកការផ្លាស់ប្តូរ និងភាពច្នៃប្រឌិត ផ្នែកបច្ចេកវិទ្យា ដើម្បីក្លាយជាអ្នកនាំមុខគេនៅក្នុងទីផ្សារ។ |
| គាំពារ | យើងជួយ និងយកចិត្តទុកដាក់ចំពោះអតិថិជន តាមរយៈការធ្វើការរួមគ្នាដើម្បីកសាងអនាគតឱ្យកាន់តែប្រសើរ។ |
| ថាមវន្ត | យើងមានសុទិដ្ឋិនិយម និងសេចក្តីស្វាហាប់ដើម្បីដឹកនាំ និងធ្វើការរួមគ្នាក្នុងបរិយាកាសបើកទូលាយដើម្បីសម្រេចគោលដៅរបស់យើង។ |
| សាមញ្ញ | យើងធ្វើអ្វីៗឱ្យមានលក្ខណៈសាមញ្ញ ងាយស្រួល និងសមស្របសម្រាប់អតិថិជនដោយផ្អែកលើតម្រូវការរបស់ពួកគាត់ជាអទិភាព។ |

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ត្រីមាសទី៣ឆ្នាំ២០១៩ | ដំណាច់ការិយបរិច្ឆេទឆ្នាំ ២០១៨ |
|---|---|---|
| ទ្រព្យសកម្មសរុប (លានរៀល) | ៤ ៥៦០ ៤៥៤ | ៣ ៧១៦ ៩៦៦ |
| បំណុលសរុប (លានរៀល) | ៣ ៧៩៦ ៧១៥ | ៣ ០៤៨ ៩៩៦ |
| មូលធនសរុប (លានរៀល) | ៧៦៣ ៧៣៨ | ៦៦៧ ៩៧០ |
| **លទ្ធផលហិរញ្ញវត្ថុ** | **ត្រីមាសទី៣ឆ្នាំ២០១៩** | **ត្រីមាសទី៣ឆ្នាំ២០១៨** |
| ចំណូលសរុប (លានរៀល) | ១៥៥ ៤៤៧ | ១២០ ៨៦០ |
| ចំណេញ/(ខាត)មុនបង់ពន្ធ (លានរៀល) | ៤០ ៣៦០ | ២៧ ៩៦៥ |
| ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ (លានរៀល) | ៣២ ២៥៤ | ២២ ២៩៩ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ (លានរៀល) | ៣៤ ៦៥២ | ២៤ ៨២៦ |
| **អនុបាតហិរញ្ញវត្ថុ** | **ត្រីមាសទី៣ឆ្នាំ២០១៩** | **ដំណាច់ការិយបរិច្ឆេទឆ្នាំ ២០១៨** |
| អនុបាតសាធនភាព (ភាគរយ) | ១៦,៩ | ២០,០ |
| អនុបាតបំណុលធៀបនឹងមូលធន (ភាគរយ) | ៤៩៧ | ៤៥៦ |
| អនុបាតសន្ទនីយភាព (ភាគរយ) | ១៤៦,៩ | ១៧៧,០ |
| អនុបាតឥណទានមិនដំណើរការ[1] (ភាគរយ) | ០,៣៥ | ០,៦៧ |
| អនុបាតបញ្ញើឥណទាន (ភាគរយ) | ៦១,៧ | ៦៣,៤ |
| | **ត្រីមាសទី៣ឆ្នាំ២០១៩** | **ត្រីមាសទី៣ឆ្នាំ២០១៨** |
| អនុបាតចំណេញភាពធៀបនឹងទ្រព្យសកម្ម (ភាគរយ) | ០,៧៦ | ០,៧០ |
| អនុបាតចំណេញភាពធៀបនឹងមូលធន (ភាគរយ) | ៤,៥៤ | ៣,៧៨ |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ភាគរយ) | ១៦៤ | ១៥៧ |



[1] និយមន័យរបស់ធនាគារជាតិនៃកម្ពុជា

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប






# សមាសភាពក្រុមប្រឹក្សាភិបាល



លោក **Sudargo Harsono**
ប្រធានក្រុមប្រឹក្សាភិបាល



លោក ហួត អៀងតុង
អភិបាល



កញ្ញា **Duangdao Wongpanitkrit**
អភិបាល



លោក **Rohit Khanna**
អភិបាល



លោក **Chandrashekar S.K.**
អភិបាល



លោក **Wanchairabin Jitwattanatam**
អភិបាល



លោក ឡូញ ហៃ
អភិបាលឯករាជ្យ



លោក ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ



លោក ប៉ាក សេរីវឌ្ឍនា
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ក្នុងនាមជាអ្នកបោះផ្សាយមូលបត្របំណុលសាជីវកម្មដំបូងបង្អស់នៅកម្ពុជា តាំងពីខែវិច្ឆិកាឆ្នាំ ២០១៨ ជាមួយទឹកប្រាក់ចំនួន ១២០ ប៊ីលានរៀល (៣០ លានដុល្លារអាមេរិក) ហត្ថាកសិករលីមីតធីត មានមោទនភាពដែលបានបោះជំហានមុនគេក្នុងការលើកកម្ពស់ទីផ្សារមូលបត្របំណុលកម្ពុជាក៏ដូចជារូបិយវត្ថុប្រាក់រៀល។ ហើយឆ្លៀតក្នុងឱកាសនេះយើងសូមជម្រាបជូនដល់សាធារណជននិងដៃគូពាណិជ្ជកម្មឱ្យបានជ្រាបពីដំណើរវិវឌ្ឍន៍និងបច្ចុប្បន្នភាពនៃព្រឹត្តិការណ៍មួយចំនួនក្នុងត្រីមាសទី៣ដូចខាងក្រោម៖

ហត្ថាកសិករលីមីតធីតបន្តផ្តល់សេវាកម្មនិងផលិតផលថ្មីៗដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍន៍ និងតម្រូវការរបស់អតិថិជន។ នៅក្នុងខែកក្កដាយើងបានណែនាំផលិតផលឥណទានថ្មីមួយមានឈ្មោះថា First Choice ដែលអតិថិជនអាចប្រើប្រាស់ឥណទាននេះ ក្នុងការទិញទូរស័ព្ទចល័ត ផលិតផលអេឡិចត្រូនិច និងឧបករណ៍ប្រើប្រាស់ក្នុងផ្ទះបានកាន់តែងាយស្រួល។ ឥឡូវនេះអតិថិជនអាចទទួលបានរបស់ទាំងនេះដោយភាពងាយស្រួលជាមួយនឹងតម្លៃសមរម្យនៅហាងដៃគូរបស់យើង។ នៅក្នុងខែសីហាយើងបានអនុវត្តយុទ្ធនាការផ្ទៃក្នុងដែលមានឈ្មោះថា 'I Love HKL' ដើម្បីលើកកម្ពស់ទស្សនវិស័យបេសកកម្ម តម្លៃស្នូល និង អត្តសញ្ញាណថ្មីរបស់ក្រុមហ៊ុន តាមរយៈជំនួបផ្ទាល់ជាមួយបុគ្គលិកជាង ១ ៥០០ នាក់នៅទូទាំងប្រទេសក្នុងកម្មវិធីCaravan Tour ដើម្បីជំរុញនិងលើកកម្ពស់ឱ្យនិយោជិករបស់យើង យល់ដឹង កាន់តែច្បាស់ពីទិសដៅថ្មីសម្រាប់ការរីកចម្រើននាពេលអនាគតក៏ដូចជាដើម្បីឱ្យពួកគាត់ ចាប់យកគោលការណ៍ស្នូលថ្មី ក្នុងការពង្រឹងវិជ្ជាជីវៈនិងបម្រើអតិថិជនឱ្យបានល្អបំផុត។

នៅត្រីមាសទី ៣ ឆ្នាំ ២០១៩ យើងបានបន្តដំណើរការអាជីវកម្មរឹងមាំ ខណៈពេលដែលជំរុញស្តង់ដារកែលម្អប្រតិបត្តិការរបស់យើងឆ្ពោះទៅកាន់ស្តង់ដារធនាគារជាពិសេសយើងតែងតែយកចិត្តទុកដាក់ ក្នុងការផ្តល់សេវាកម្មទូទៅ ពិសេសសេវាឥណទានប្រកបដោយតម្លាភាព និងមិនលំអៀង។ គិតត្រឹមថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៩ ផលប័ត្រឥណទានមានចំនួន ៩៤៧លានដុល្លារអាមេរិក ជាមួយកំណើនវិជ្ជមាន ៧,៤៦% បើធៀបនឹងត្រីមាសមុន។ យើងបន្តបម្រើអតិថិជនទាំងបុគ្គល និងអាជីវកម្មខ្នាតតូចបានយ៉ាងល្អប្រសើរជាមួយនឹងបណ្តាញដ៏រឹងមាំរបស់យើងនៅទូទាំងប្រទេស ដែលបានធ្វើឱ្យទាំងជីវភាពរស់នៅ និងលទ្ធផលអាជីវកម្មរបស់ពួកកាន់តែប្រសើរឡើងថែមទៀត។ ផលប័ត្រឥណទានយឺតយ៉ាវ ៣០ ថ្ងៃ បានគ្រប់គ្រងបានយ៉ាងល្អគឺស្ថិតក្នុងកម្រិតទាបត្រឹមតែ ០,៤៦% ។ ប្រាក់បញ្ញើសន្សំបានកើនឡើងដល់ ៥៨៤ លានដុល្លារអាមេរិក ជាមួយអត្រាកំណើន ៣,៨២%ធៀបនឹងត្រីមាសមុន។ លទ្ធផលអាជីវកម្មទូទៅបានបង្ហាញពីជំហរល្អជាងឆ្នាំមុន។ ចំនួនបុគ្គលិករបស់យើងកើនឡើងដល់ ៤ ២៣៥នាក់ ដែលពោរពេញដោយសមត្ថភាពខ្ពស់ក្នុងការផ្តល់ការរីកចម្រើនដល់ស្ថាប័ននិងជ្រោមជ្រែងដល់អតិថិជន។

ខ្ញុំសង្ឃឹមថាយើងនឹងបន្តផ្តល់នូវដំណោះស្រាយហិរញ្ញវត្ថុដែលអាចទុកចិត្តបាននិងប្រកបដោយភាពច្នៃប្រឌិតដល់អតិថិជនរបស់យើងដើម្បីបំពេញតាមតម្រូវការនិងកំណើនប្រកបដោយចីរភាព។

កាលបរិច្ឆេទ៖ ២៤-វិច្ឆិកា-២០១៩

ហត្ថលេខា និង ត្រា

ហត្ថាកសិករ លីមីតធីត
HKL
Head Office
HATTHA KAKSEKAR LIMITED

លោក Sudargo Harsono

ប្រធានក្រុមប្រឹក្សាភិបាល

# សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត បានខិតខំប្រឹងប្រែងបំពេញការងាររួមគ្នាដោយមានការចូលរួមពីសំណាក់បុគ្គលិក និងគណៈគ្រប់គ្រង ព្រមទាំងម្ចាស់ភាគហ៊ុនធនាគារ Ayudhya ដែលជាធនាគារឈានមុខគេមួយនៅក្នុងប្រទេសថៃ និងជាសមាជិករបស់ MUFG ក្នុងការធ្វើឲ្យគ្រឹះស្ថាននេះ ត្រៀមខ្លួនរួចជាស្រេច សម្រាប់ការក្លាយខ្លួនទៅជាធនាគារពាណិជ្ជទាំងធនធានមនុស្ស ដើមទុន និងបច្ចេកវិទ្យាព័ត៌មាន ដើម្បីបម្រើសេវាកម្ម និងផលិតផលហិរញ្ញវត្ថុប្រកបដោយវិជ្ជាជីវៈ សច្ចៈ ស្មោះត្រង់ និងសាមញ្ញ ជាមួយនឹងទស្សនវិស័យឌីជីថលកាន់តែទំនើបជូនអតិថិជន។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត សូមប្រកាសបង្ហាញសមិទ្ធផលគិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ អតិថិជនឥណទានសរុបមានចំនួន ១៥៩ ៧៤៨នាក់ អតិថិជនដាក់ប្រាក់បញ្ញើសន្សំមានចំនួន ២៥២ ១២០ នាក់ និង អតិថិជនប្រើប្រាស់ប័ណ្ណអេធីអឹមចំនួន ៤៧ ៧៧២នាក់។ ផលប័ត្រឥណទាន កើនឡើងដល់ ៩៤៧លាន ដុល្លារអាមេរិក និង ផលប័ត្រប្រាក់បញ្ញើសន្សំ បានកើនឡើងដល់ ៥៨៤លានដុល្លារអាមេរិក ដែលបង្ហាញពីទំនុកចិត្តខ្ពស់បំផុតពីអតិថិជន និងសាធារណជនមកកាន់ហត្ថាកសិករ លីមីតធីត ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ លីមីតធីត មានបណ្តាញប្រតិបត្តិការចំនួន ១៧៧សាខា ជាមួយនឹងម៉ាស៊ីន ATM ចំនួន១២៩ នៅទូទាំងប្រទេស។ បុគ្គលិកសរុបមាន ៤ ២៣៥នាក់ កំពុងផ្តល់ជូនសេវាកម្មហិរញ្ញវត្ថុដ៏ល្អបំផុត តាមរយៈបណ្តាញសាខាយ៉ាងធំទូលំទូលាយទូទាំងផ្ទៃប្រទេស។

នៅក្នុងផ្នែកឌីជីថល ហត្ថាកសិករ លីមីតធីត នៅតែបន្តនាំយកបច្ចេកវិទ្យាជឿនលឿន និងទំនើបថ្មីៗ ព្រមទាំងទាញជាប្រយោជន៍សម្រាប់គ្រប់សកម្មភាពប្រតិបត្តិការទាំងអស់ ដើម្បីឆ្លើយតបតាមតម្រូវការរបស់អតិថិជនឱ្យទទួលបានបច្ចុប្បន្នភាព និងនិរន្តរភាពក្នុងសម័យឌីជីថល។ យើងបន្តពង្រីកប្រព័ន្ធធនាគារចល័តតាមរយៈទូរស័ព្ទ និងដាក់ឲ្យដំណើរការបន្ថែមនូវប្រតិបត្តិការធនាគារតាមរយៈInternet ដោយបច្ចុប្បន្នការប្រើប្រាស់សេវាកម្មធនាគារតាមប្រព័ន្ធអេឡិចត្រូនិចរបស់យើងមានចំនួន ៧ ៧៩៦នាក់ ដែលផ្តល់ជូនសេវាយ៉ាងល្អតាមរយៈក្រុមការងារ ដែលមានបទពិសោធន៍ខ្ពស់។ ហត្ថាកសិករ លីមីតធីត បន្តខិតខំផ្តល់ជូនសេវាកម្មហិរញ្ញវត្ថុឈានមុខគេមួយ ដែលមានភាពងាយស្រួល និងជឿទុកចិត្តពីសំណាក់អតិថិជន និងសាធារណជន។ នៅខែឧសភា ឆ្នាំ ២០១៨ ហត្ថាកសិករ លីមីតធីត មានមោទនភាពក្នុងការទទួលបានចំណាត់ថ្នាក់ «BBB+» ពីភ្នាក់ងារវាយតម្លៃអន្តរជាតិ TRIS ដែលបានបញ្ជាក់ពីប្រតិបត្តិការមានស្ថេរភាពជាមួយនឹងជំហររឹងមាំក្នុងទីផ្សារកម្ពុជា។ ចំណុចវាយតម្លៃរួមមានដូចជា បណ្តាញសាខាទូទាំងប្រទេស ភាពចម្រុះនៃប្រភេទអតិថិជន ប្រព័ន្ធគ្រប់គ្រងហានិភ័យល្អ, ការគ្រប់គ្រងហិរញ្ញវត្ថុ និងសាច់ប្រាក់រឹងមាំ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ ដែលបានប្តេជ្ញាចិត្តធ្វើឱ្យសម្រេចសមិទ្ធផលដ៏អស្ចារ្យនេះ។ ខ្ញុំសូមកោតសរសើរ និងដឹងគុណចំពោះទំនុកចិត្ត និងការគាំទ្រពីសំណាក់អតិថិជន ដៃគូអាជីវកម្ម និងសាធារណជន ហើយខ្ញុំសង្ឃឹមនិងជឿជាក់ថា នឹងផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុស្តង់ដាខ្ពស់បំផុត ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩

លោក ហួត អៀងតុង
ប្រធានអគ្គនាយក

# មាតិកា


ទស្សនវិស័យ និងបេសកកម្ម ........ i

តម្លៃស្នូល ........ i

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ii

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ iii

សមាសភាពក្រុមប្រឹក្សាភិបាល ........ iv

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ v

សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក ........ vi

ផ្នែកទី ១ : ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ ........ ១

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១

ខ- លក្ខណៈនៃធុរកិច្ច ........ ១

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ២

ផ្នែកទី ២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ២

ក.លទ្ធផលប្រតិបត្តិការធុរកិច្ច ........ ២

ខ-រចនាសម្ព័ន្ធចំណូល ........ ៣

ផ្នែកទី ៣ : របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ ........ ៤

ផ្នែកទី ៤: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ........ ៥

ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ ៥

ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ ៥

គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ ៥

ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ ៥

ង-ផលប៉ះពាល់នៃអតិផរណា ........ ៦

ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ........ ៦

# ផ្នែកទី ១ : ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ

## ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ហត្ថាកសិករលីមីតធីត |
| ឈ្មោះជាអក្សរឡាតាំង | Hattha Kaksekar Limited |
| អក្សរកូដ | HKL |
| អាសយដ្ឋាន | អគារលេខ ៦០៦ ផ្លូវ២៧១ ភូមិសន្សំកុសល ៣ សង្កាត់បឹងទំពន់ ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | ០២៣ ៩៩៤ ៣០៤ |
| គេហទំព័រ | www.hkl.com.kh |
| អ៊ីម៉ែល | info@hkl.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៥៣៥៥ (ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០១) |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ម.ហ ០២-១២/០៦/១១/០១ ចេញដោយ: ធនាគារជាតិនៃកម្ពុជា កាលបរិច្ឆេទ: ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ ១៦៥/១៨គ.ម.ក. កាលបរិច្ឆេទ: ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ |
| តំណាងHKLដោយ | លោក ហួត អៀងតុង |

## ខ- លក្ខណៈនៃធុរកិច្ច

ហត្ថាកសិករលីមីតធីត គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើសន្សំធំមួយ ទទួលបានអាជ្ញាប័ណ្ណ ពីធនាគារជាតិនៃកម្ពុជា និងបានធ្វើប្រតិបត្តិការជាង ២៥ឆ្នាំ មកហើយ។ ហត្ថាកសិករលីមីតធីត បាននឹងកំពុងផ្តល់សេវាកម្មហិរញ្ញវត្ថុយ៉ាង សម្បូរបែបដល់អតិថិជនដូចជា៖ សេវាឥណទាន សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុក សេវាអេធីអឹម សេវាធនាគារចល័ត សេវាបើកប្រាក់បៀវត្ស និងជាអ្នកណែនាំលក់សេវាធានារ៉ាប់រងផងដែរ តាមរយៈសាខាចំនួន ១៧៧ និងម៉ាស៊ីនអេធីអឹមចំនួន ១២៩ ទីតាំងនៅទូទាំងប្រទេស។ គិតត្រឹមខែកញ្ញា ឆ្នាំ ២០១៩ សមតុល្យប្រាក់បញ្ញើសន្សំ របស់ហត្ថាកសិករលីមីតធីត មានចំនួនជាង ៥៨៤ លានដុល្លារអាមេរិក ជាមួយនឹងចំនួន អតិថិជនប្រាក់បញ្ញើសន្សំជាង ២៥២ ១២០ នាក់ ជាមួយផលប័ត្រឥណទានសរុបមាន ចំនួនប្រមាណ ៩៤៧ លានដុល្លារអាមេរិក ដែលបម្រើអតិថិជន ចំនួនជាង ១៥៩ ៧៤៨ នាក់។ បច្ចុប្បន្ន ហត្ថាកសិករលីមីតធីត គឺជាបុត្រសម្ព័ន្ធរបស់ធនាគារ Krungsri ដែលជាធនាគារពាណិជ្ជធំជាងគេលំដាប់ទី ៥ នៅព្រះរាជាណាចក្រថៃ និងជាសមាជិករបស់សម្ព័ន្ធហិរញ្ញវត្ថុអន្តរជាតិ Mitsubishi UFJ Financial Group (MUFG) ដែលជាសម្ព័ន្ធធនាគារធំជាងគេបំផុតនៅប្រទេសជប៉ុន ព្រមទាំងជាសម្ព័ន្ធសេវាហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោម សម្ព័ន្ធហិរញ្ញវត្ថុ ធំជាងគេលើសកលលោក។

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ហត្ថាកសិករលីមីតធីតបានបន្តនូវវឌ្ឍនភាពល្អៗជាច្រើនដូចជា កំណើនសម្មៀតឥណទាន និងកំណើននៃការប្រើប្រាស់ និងការគាំទ្រពីសាធារណជនលើផលិតផលហិរញ្ញវត្ថុផ្សេងៗ។ ដើម្បីឆ្លើយតបនូវតម្រូវការ និងការវិវឌ្ឍន៍ទៅនៃទីផ្សារដែលមានលក្ខណៈកាន់តែប្រកួតប្រជែង ហត្ថាកសិករលីមីតធីតបានបង្កើនវិសាលភាពនៃផលិតផលឥណទានឱ្យបានកាន់តែទូលំទូលាយ ដោយបាញ់ឆ្ពោះទៅរកផលិតឥណទានប្រើប្រាស់ ជាពិសេសសម្រាប់អតិថិជន ដែលមានតម្រូវការច្រើនក្នុងការធ្វើឱ្យជីវភាពរស់នៅកាន់ តែទំនើបទាន់សម័យ ដោយហត្ថាកសិករលីមីតធីតបានដាក់ឱ្យប្រើប្រាស់នូវផលិតផល First Choice ដែលបានផ្តល់លទ្ធភាពឱ្យអតិថិជនអាចទិញបាននូវផលិតផលប្រើប្រាស់ខ្លួនចង់បានភ្លាមៗតាមរយៈឥណទានរបស់ហត្ថាកសិករលីមីតធីត។

តាមរយៈផលិតផលនិងកម្មវិធី First Choice នេះ ហត្ថាកសិករលីមីតធីតក៏បានសហការជាមួយដៃគូធំៗជាច្រើន ដូចជា Smart Mobile, Huawei ហាងលក់ទូរស័ព្ទ និងសម្ភារៈជាច្រើនដើម្បីផ្តល់ជម្រើសដល់អតិថិជនតាមតម្រូវការជាក់ស្តែង។

បន្ថែមលើនេះហត្ថាកសិករលីមីតធីតតែងតែយកចិត្តទុកដាក់ដល់ការផ្តល់សេវាកម្មដល់អតិថិជន ជាពិសេសតាមរយៈសកម្មភាពនៃការបណ្តុះបណ្តាល និងផ្សារភ្ជាប់ឱ្យបុគ្គលិកមានសមត្ថភាពកាន់ប្រសើរ ដែលជាក់ស្តែងនៅក្នុងខែសីហា យើងបានអនុវត្តយុទ្ធនាការផ្ទៃក្នុងដែលមានឈ្មោះថា ' I Love HKL' ដើម្បីលើកកម្ពស់ទស្សនវិស័យ បេសកកម្ម តម្លៃស្នូល និង អត្តសញ្ញាណថ្មីរបស់ហត្ថាកសិករលីមីតធីត តាមរយៈជំនួបផ្ទាល់ជាមួយបុគ្គលិកជាង ១៥០០នាក់ នៅទូទាំងប្រទេសក្នុងកម្មវិធី Caravan Tour ដើម្បីជំរុញនិងលើកកម្ពស់ឱ្យនិយោជិករបស់យើង យល់ដឹងល្អពីទិសដៅថ្មីសម្រាប់ការរីកចម្រើននាពេលអនាគតក៏ដូចជាដើម្បីឱ្យពួកគាត់ ចាប់យកគោលការណ៍ស្នូលថ្មីដើម្បីពង្រឹងវិជ្ជាជីវៈនិងបម្រើអតិថិជនឱ្យបានល្អបំផុត។

## ផ្នែកទី ២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច

| លទ្ធផលសម្រេចបានសំខាន់ៗ នាខែកញ្ញា ឆ្នាំ២០១៩ | ផែនការ | លទ្ធផលសម្រេចបាន |
|---|---|---|
| ផ្នែកសេវាឥណទាន | | |
| ចំនួនគណនីសេវាឥណទាន | ១៥៣ ០៥២ | ១៥៩ ៧៥៨ |
| ឥណទាននៅក្នុងដៃអតិថិជន (ពាន់ដុល្លារអាមេរិក) | ៨៩០ ៨១៩ | ៩៤៦ ៩១៥ |
| ផ្នែកសេវាប្រាក់បញ្ញើសន្សំ | | |
| ចំនួនគណនីសេវាប្រាក់បញ្ញើសន្សំ | ២៦៤ ២៤១ | ២៥២ ១២០ |
| សមតុលប្រាក់បញ្ញើសន្សំ (ពាន់ដុល្លារអាមេរិក) | ៥៣៤ ៦៣៩ | ៥៨៤ ៤៨០ |
| ផ្នែកសេវាកម្មផ្សេងៗទៀត | | |
| ចំនួនអ្នកប្រើប្រាស់កាតអេធីអឹម | ៥៤ ៨៣៩ | ៤៧ ៧៧២ |

| | | |
|---|---|---|
| ចំនួនអ្នកប្រើប្រាស់សេវាធនាគារចល័ត | ៨ ៣៩៧ | ៧ ៧៩៦ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងខ្នាតតូច (ដុល្លារអាមេរិក) | ៤៥៣ ៥៦០ | ៤១៨ ៧៧៩ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិតឥណទាន (ដុល្លារអាមេរិក) | ១ ១៨៣ ២៥៥ | ៣ ៣៦៩ ៥៨៧ |
| ផ្នែកប្រតិបត្តិការសំខាន់ផ្សេងៗទៀត | | |
| ចំនួនការិយាល័យ | ១៧៧ | ១៧៧ |
| ចំនួនអេធីអឹម | ១២៩ | ១២៩ |
| ចំនួនបុគ្គលិក | ៤ ២៤៦ | ៤ ២៣៥ |

## ខ-រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី៣ ឆ្នាំ ២០១៩ | | ត្រីមាសទី៣ ឆ្នាំ ២០១៨ | |
|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | ១៤៩ ៤០៦ | ៩៦,១ | ១១៥ ៥៩៣ | ៩៥,៦ |
| ២ | ចំណូលផ្សេងៗ | ៦ ០៤១ | ៣,៩ | ៥ ២៦៧ | ៤,៤ |
| | ចំណូលសរុប | ១៥៥ ៤៤៧ | | ១២០ ៨៦០ | |

## ផ្នែកទី ៣ : របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលរបាយការណ៍លម្អិតនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ។

## ផ្នែកទី ៤: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ ដោយ គណៈគ្រប់គ្រងរបស់ ហត្ថាកសិករលីមីតធីត ដោយផ្អែកទៅលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹម ថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ ២០១៩ ហើយដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ គិតត្រឹមថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ ២០១៩។ របាយការណ៍ហិរញ្ញវត្ថុទាំងនេះរបស់ហត្ថាកសិករលីមីតធីតត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារ របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗ ដែលបាន ជះឥទ្ធិពលទៅលើប្រាក់ចំណេញរបស់ហត្ថាកសិករលីមីតធីតតែប៉ុណ្ណោះ ។

### ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ការវិភាគចំណូល

ហត្ថាកសិករលីមីតធីតមានចំណូល ២ប្រភេទធំៗគឺ ចំណូលពីការប្រាក់ និងចំណូលផ្សេងៗ

| | |
|---|---|
| **ចំណូលពីការប្រាក់រួមមាន៖** ចំណូលការប្រាក់សុទ្ធដែលទទួលបានពីការផ្តល់ឥណទានដល់ អតិថិជន និងពីការដាក់ប្រាក់បញ្ញើនៅតាមបណ្តា ធនាគារនានា។ ហើយចំណូលទាំងនេះត្រូវទទួលស្គាល់ជាប្រចាំខែ។ | **ចំណូលផ្សេងៗរួមមាន៖** កម្រៃណែនាំ កម្រៃផ្ទេរប្រាក់ចំណូលកម្រៃផ្សេងៗ ចំណូលបាន មកពីការប្រមូលឥណទានលុបចោល ចំណេញពីការប្តូរប្រាក់ ។ល។ |

ចំណូលការប្រាក់ ជាចំណូលដ៏ធំនិងសំខាន់សម្រាប់ ហត្ថាកសិករលីមីតធីតដែលមានរហូតដល់ ៩៦.១% នៃចំណូលសរុប។

### ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ ២០១៩ នេះ គណៈគ្រប់គ្រង់យល់ថា ហត្ថាកសិករលីមីតធីត ពុំមានធាតុ ដែលខុសពីធម្មតាទេ។

### គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី ៣០ខែ កញ្ញា ឆ្នាំ ២០១៩នេះ គណៈគ្រប់គ្រងយល់ថា ហត្ថាកសិករលីមីតធីត ពុំមានធាតុដែលជាការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូលខុសពីធម្មតាទេ។

### ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ហត្ថាកសិករលីមីតធីត បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ ប្រាក់ដុល្លារអាមេរិក។ ប្រតិបត្តិការជា រូបិយវត្ថុ ប្រាក់រៀល និងរូបិយប័ណ្ណប្រាក់ថៃបាត ត្រូវបានប្តូរទៅជា រូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និង ខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ ការប្តូរទ្រព្យសកម្មនិងបំណុល រូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រា នៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

**ង-ផលប៉ះពាល់នៃអតិផរណា**

ហត្ថាកសិករ លីមីតធីតមិនបានកែប្រែអត្រាការប្រាក់ដោយផ្អែកតាមការប្រែប្រួលនៃអតិផរណាទេ ពោលគឺផ្អែកទៅលើស្ថានភាព ប្រកួតប្រជែងជាក់ស្តែងនៅក្នុងទីផ្សារ ហើយនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុយ៉ាងល្អប្រសើរ។

**ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល**

នៅត្រីមាសទី ៣ ក្នុងឆ្នាំ២០១៩ ដើម្បីទាក់ទាញអ្នកវិនិយោគទុនក្រៅប្រទេសក៏ដូចជាការលើកទឹកចិត្តអ្នកវិនិយោគទុននៅក្នុងប្រទេស និងដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិឱ្យរីកលូតលាស់កាន់តែខ្លាំងបន្ថែមទៀត រាជរដ្ឋាភិបាលបានធ្វើដាក់ចេញឱ្យអនុវត្តនូវគោលនយោបាយទាក់ទងនឹងវិស័យហិរញ្ញវត្ថុមួយចំនួនដូចជា៖

- ធនាគារជាតិនៃកម្ពុជា បានចេញសេចក្តីណែនាំស្តីអំពី ការគ្រប់គ្រងហានិភ័យផ្នែកព័ត៌មានវិទ្យា ក្នុងគោលបំណងជួយឱ្យស្ថាប័នហិរញ្ញវត្ថុទាំងអស់ ព្រមទាំងអតិថិជនរបស់ខ្លួនមានសុវត្ថិភាពខ្ពស់ក្នុងការធ្វើដំណើរការអាជីវកម្ម/ប្រតិបត្តិការរបស់ខ្លួន។
- ដើម្បីបន្តរក្សាបាននូវស្ថេរភាពថ្លៃ សំដៅរួមចំណែកគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចេរភាព ធនាគារជាតិនៃកម្ពុជា បានសម្រេចបន្តអនុវត្តនូវគោលនយោបាយរូបិយវត្ថុមួយចំនួនដូចជា ១). បន្តរក្សាស្ថេរភាពនៃអត្រាប្តូរប្រាក់ដោយប្រកាន់យករបបអត្រាប្តូរប្រាក់ដែលមានស្ថេរភាព តាមរយៈការធ្វើអន្តរាគមន៍ផ្អែកលើការប្រែប្រួលនៃទីផ្សារ ២). បន្តផ្គត់ផ្គង់សន្ទនីយភាពជាប្រាក់រៀល សម្រាប់បំពេញតម្រូវការគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ៣). ដាក់ឱ្យអនុវត្តឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី នៅត្រីមាសទី ៤ ឆ្នាំ២០១៩ ៤). បន្តលើកកំពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ តាមរយៈការបង្កើនការយល់ដឹងពីសាធារណជនអំពីសារៈសំខាន់និងតួនាទីប្រាក់រៀលក្នុងសេដ្ឋកិច្ច និងសង្គម ៥). ពង្រឹងការអនុវត្តសេចក្តីសម្រេចរបស់ធនាគារជាតិនៃកម្ពុជាស្តីពីការតម្រូវឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានកម្ចីជាប្រាក់រៀលយ៉ាងតិច ១០% ក្នុងឆ្នាំ ២០១៩។

ហត្ថលេខារបស់អភិបាល ហត្ថាកសិករ លីមីតធីត បានឃើញ និងឯកភាព នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩។

| | |
|---|---|
| លោក ឡុញ ហៃ | លោក ឌី ដាវុឌ្ឍ |
| អភិបាលឯករាជ្យ | អភិបាលឯករាជ្យ |

កាន់តែទុកចិត្ត កាន់តែចំរើន

ហត្ថាកសិករ លីមីតធីត

HATTHA KAKSEKAR LIMITED

**Subsidiary of krungsri bank**

A member of MUFG, a global financial group